# ប្រពលវប្បកម្មដំណាំស្រូវ
# តាមគោលការណ៍ធម្មជាតិ (ប.វ.ស)

I- **សារៈប្រយោជន៍របស់ប.វ.ស**

ប្រពន្ធ័ប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ដែលហៅថា " ប.វ.ស " មានសារៈប្រយោជន៍ដូចជា៖

- ស្រូវលូតលាស់បានល្អ
- បែកគុម្ពបានច្រើនអាចពី ៥០-៦០ដើម
- មានកួរច្រើន កួរវែង
- គ្រាប់ធំ និង គ្រាប់ច្រើន
- អង្ករមានរស់ជាតិឆ្ងាញ់
- កាត់បន្ថយការពុលបរិស្ថាន

II- **គុណសម្បត្តិរបស់ ប.វ.ស**

តាមបទពិសោធន៍កន្លងមក

- អាចបង្កើនទិន្នផលស្រូវ ២-៣ដងលើសធម្មតា
- កាត់បន្ថយការចំណាយលើពូជ
- កាត់បន្ថយការចំណាយលើជីគីមី និង ថ្នាំពុល
- ការជួលកំលាំងពលកម្មសំរាប់ស្ទូង និងដកសំណាបថែមទៀតផង ។

III -**វដ្តជីវិតរបស់ដំណាំស្រូវ**

ការលូតលាស់របស់ដំណាំស្រូវ ត្រូវបានចែកចេញជា **៣វគ្គ** សំខាន់ៗ គឺ

**៣ វគ្គ**

| **វគ្គ លូតលាស់** | **វគ្គ បង្កបង្កើតផល** | **វគ្គ ទុំ** |
|---|---|---|
| រយៈពេលប្រែប្រួលទៅតាម អាយុប្រភេទពូជស្រូវ ( ស្រាល ឬកណ្តាល ឬធ្ងន់ ) | មានរយៈពេល ៣៥ថ្ងៃ | មានរយៈពេល ៣០ថ្ងៃ |

**១ វដ្តជីវិតរបស់ដំណាំស្រូវ មាន ១០ ដំណាក់កាល**

| ដំណាក់កាលទាំង ១០ និងការបរិយាយ | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ***ដុះពន្លក*** | ***សំណាប*** | ***បែកគុម្ព*** | ***ពន្លូតដើម*** | ***កំណើតកួរ*** | ***ផើម*** | ***ចេញកួរ+ផ្កា*** | ***ដាក់ទឹកដោះ*** | ***ដាក់ម៉្សៅ*** | ***ទុំ*** |
| ចាប់ពីដុះពន្លកដល់មានស្លឹកទី១ក្នុងដើម | ចាប់ពីស្លឹកទី១ ដល់មានក្មេង | ពីបែកគុម្ពតំបូងដល់បែកគុម្ពពេញទំហឹង ***(បំប៉នជីលើកទី១)*** | ពីបែកគុម្ពពេញទំហឹងដល់ចាប់ពន្លកកកួរ (បំប៉នជីលើកទី២) | ពីកកើតកួរដំបូងដល់មានរាងជាត្រីកោណ ១-២,៥ មីលីម៉ែត្រ | ចាប់កំនើតកកួរដល់មានជាស្រកីក្នុងផើម | ពីស្រកីចេញពីស្រទបស្លឹកទៅជាផ្កា | ទឹកដោះរាវ (អាចហូរបាន) | ពីទឹកដោះរាវទៅទឹកដោះរឹង | ពីម៉្សៅរឹងទៅទុំ |

| វគ្គលូតលាស់មាន ៤ ដំណាក់កាល | វគ្គបង្កបង្កើនផលមាន ៣ ដំណាក់កាល | វគ្គទុំមាន ៣ ដំណាក់កាល |
|---|---|---|

***<u>ត្រូវចងចាំ:</u>***

- នៅក្នុងវគ្គលូតលាស់ អ្នកត្រូវគិតពី ការរៀបចំពូជ ការពិនិត្យគុណភាពគ្រាប់ពូជ ការត្រាំនិងបណ្តុះគ្រាប់ពូជ ការជ្រើសរើស និងរៀបចំទីកន្លែងសំរាប់សាប ការថែទាំសំណាប ការរៀបចំដីសំរាប់ស្ទូង ការដាក់ជី និង ការថែទាំសន្ទូង ។
- នៅក្នុងវគ្គបង្កបង្កើនផល ចាំបាច់ត្រូវថែទាំទឹកអោយបានល្អ បាចជីបំប៉ន និង កំចាត់សត្វល្អិតចង្រៃ និងកណ្តុរ ។
- នៅក្នុងវគ្គទុំ អ្នកត្រូវប្រុងប្រយត្ន័ លើបញ្ហាមួយចំនួយដូចជាការបំផ្លាញរបស់ស្រឹង កណ្តុរ ចាប និង ពេលវេលានៃការប្រមូលផល ។




វិគ្គលូតលាស់




IV- **គោលការណ៍ និង បច្ចេកទេស ប.ទ.ស**

តាមលក្ខណៈធម្មជាតិរបស់វាអាចបែកគុម្ពបានរហូតដល់ ៥០-៦០ ដើម ឬជួនកាល១០០ដើម (ឧ. ស្រូវម្សូរ)

**១/ គោលការណ៍របស់ ប.ទ.ស**

- ដំណាំស្រូវមិនមែនជារុក្ខជាតិទឹក ប៉ុន្តែវាធន់ទ្រាំទៅនឹងទឹក ។ ប្រសិនបើដំណាំស្រូវដុះក្នុងទឹកតិចៗ នោះសក្តានុពលនៃការលូតលាស់ និង ការបែកគុម្ពរបស់វាបានល្អ
- ដំណាំស្រូវ នឹងកាត់បន្ថយសក្តានុពលធម្មជាតិក្នុងការបែកគុម្ព ប្រសិនបើអ្នកស្ទូងសំណាបមានអាយុលើស ពី ១៥ថ្ងៃឡើងទៅ។
- ដំណាំស្រូវនឹងមានសក្តានុពលបែកគុម្ពខ្ពស់ ប្រសិនបើអ្នកកាត់បន្ថយនូវភាពរន្ធត់របស់វា (ឧ. ការដក សំណាប ពីថ្នាលរួចយកមកបោកនឹងប្រអប់ជើងអ្នកខ្លាំងៗ បន្ទាប់មកយកវាមកចងវីតជាកណ្តាប់ជា ដើម ។ល ។)
- ប្រសិនបើដំណាំស្រូវដុះតែម្នាក់ឯងនោះ វានឹងលូតលាស់ហើយបែកគុម្ពតាមសក្តានុពលធម្មជាតិរបស់វា
- ដំណាំស្រូវនឹងលូតលាស់បានល្អ ប្រសិនបើដីធូរមានខ្យល់ចេញចូល និងមានជីជាតិគ្រប់គ្រាន់ ។

## ២/ បច្ចេកទេស នៃ ប.ទ.ស

បច្ចេកទេសសំខាន់ៗចំនួន **១២** នៃប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ ដើម្បីអោយស្រូវផ្តល់ **ទិន្នផលខ្ពស់** គឺៈ

- ប្រើជីធម្មជាតិ ជាពិសេសជីកំប៉ុស្ត ដើម្បីអោយដីផុសល្អ
- ប្រើពូជសុទ្ធល្អ និងរើសតែគ្រាប់ពេញល្អ សំរាប់យកទៅសាប
- ធ្វើថ្នាលសំណាបគោក ហើយសាបស្តើង ដើម្បីអោយសំណាបថ្លោសល្អ
- ដកថ្នមៗ យកតែសំណាបណាថ្លោសៗ រួយយកទៅស្ទូងភ្លាមៗ
- ស្ទូងសំណាបអាយុខ្លី យកល្អអាយុតិចជាង ១៥ថ្ងៃ
- ស្ទូងចាប់ស្តើង យកល្អស្ទូងតែ ១ដើម ក្នុង១គុម្ព
- ស្ទូងថ្នមៗ រាក់ៗ និងកុំបត់ឬសដូចផ្លែសន្ទូច
- ស្ទូងជាជួរដោយចំងាយពីគុម្ព មួយទៅគុម្ពមួយស្មើៗគ្នា
- ស្ទូងអោយរង្វើលពីគ្នា ដោយទុកចន្លោះពី ២,៥-៤តឹក
- ជៀសវាងកុំអោយមានទឹកដក់ច្រើននៅក្នុងស្រែ ពេលស្រូវកំពុងលូតលាស់
- ដកស្មៅ និង បំផុសដីអោយបាន ២-៤ដង ដើម្បីអោយខ្យល់ចេញចូលល្អ និង
- ធ្វើដីអោយបានរាបស្មើ និង មានប្រព័ន្ធសំរាប់បញ្ចេញទឹក ។

